| សេចក្តីប្រកាសសារព័ត៌មានរួម | សម្រាប់ចេញផ្សាយបន្ទាន់ |
| --- | --- |

# ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីរយៈពេល ២០ ឆ្នាំ ត្រូវបានឯកភាពទទួលយកសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតងប្រកបដោយភាពរស់រវើក និងនិរន្តរភាព

**ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី៖** នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ ២០២១ ក្រុមប្រឹក្សាខេត្ត បានឯកភាពទទួលយកផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី ហើយនេះជាកំណត់សំគាល់ប្រវត្តិសាស្ត្រមួយដែលខេត្តមណ្ឌលគិរី មានផែនការរៀបចំដែនដីរបស់ខ្លួនជាលើកដំបូង។ ក្នុងកិច្ចប្រជុំទទួលយកផែនការនេះ មានវត្តមានចូលរួមពីតំណាងមកពីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ សមាជិកក្រុមប្រឹក្សាខេត្តមណ្ឌលគិរី ទីភ្នាក់ងារសហរដ្ឋអាមេរិក សម្រាប់ការអភិវឌ្ឍអន្តរជាតិ (*USAID*) អង្គការ WWF កម្ពុជា និងក្រុមអ្នកជំនាញបច្ចេកទេសកសាងផែនការរៀបចំដែនដីផងដែរ។

នៅមុនកិច្ចប្រជុំដើម្បីឯកភាពទទួលយកផែនការរៀបចំដែនដីនេះ ភាគីពាក់ព័ន្ធមកពីក្រសួងផ្សេងៗ មន្ទីរជំនាញថ្នាក់ខេត្ត ការិយាល័យរដ្ឋបាលស្រុក ឃុំ ទីភ្នាក់ងារសហរដ្ឋអាមេរិក សម្រាប់ការអភិវឌ្ឍអន្តរជាតិ(*USAID*) និងវិស័យឯកជន បានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់សម្រេចចុងក្រោយស្តីពីផែនការរៀបចំដែនដីនៅថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០២១។

ការបង្កើតផែនការរៀបចំដែនដី ជាដំណើរការដែលមានការចូលរួមពីពហុភាគី និងត្រូវបានផ្តួចផ្តើមឡើងនៅខែមករា ឆ្នាំ ២០១៧ ដោយមានការបង្កើតឡើងនូវរចនាសម្ព័ន្ធអភិបាលកិច្ច ក្រោមការគាំទ្រថវិកាពីសហភាពអឺរ៉ុប (EU)។ ការបង្កើតផែនការរៀបចំដែនដី ត្រូវបានចាប់ផ្តើមនៅខែ តុលា ឆ្នាំ ២០១៨ ក្រោមការគាំទ្រថវិកាពីគម្រោងគាំទ្រដែនជម្រកសត្វព្រៃរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិក សម្រាប់ការអភិវឌ្ឍអន្តរជាតិ(*USAID*) តាមរយៈអង្គការ *WWF* កម្ពុជា។ ដំណើរការ កសាងផែនការរៀបចំដែនដី បានអនុវត្តដោយក្រុមអ្នកជំនាញបច្ចេកទេស រួមមាន ក្រុមការងារស្នូលរៀបចំផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី ក្រុមទីប្រឹក្សាបច្ចេកទេសដែលជ្រើសរើសដោយអង្គការ *WWF* កម្ពុជា និងបុគ្គលិកជំនាញរបស់ អង្គការ *WWF* កម្ពុជា។

ឯកឧត្តមបណ្ឌិត ម៉េង ប៊ុណ្ណារិទ្ធ អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម និងជាអគ្គលេខាធិការរងនៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ បានមានប្រសាសន៍ថា៖ “ផែនការរៀបចំដែនដីនេះ គឺជាមូលដ្ឋានគ្រឹះសម្រាប់ខេត្តមណ្ឌលគិរី ដែលមិនត្រឹមតែឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនិងការអភិវឌ្ឍនៅក្នុងយុគសម័យនៃភាវូបនីយកម្មថ្នាក់តំបន់និងសកលភាវូបនីយកម្មប៉ុណ្ណោះទេ ប៉ុន្តែវាផ្តល់ឲ្យនូវទិសដៅជាយុទ្ធសាស្ត្រ ដើម្បីកំណត់ទម្រង់នៃការអភិវឌ្ឍដែនដីខេត្តក្នុងរយៈពេល ២០ ឆ្នាំខាងមុខ។ ឯកឧត្តម បានមានប្រសាសន៍បន្ថែមទៀតថា៖ “ដូចបានធ្វើសេចក្តីសន្និដ្ឋានរួមនៅក្នុងសិក្ខាសាលាពិគ្រោះយល់ចុងក្រោយកាលពីម្សិលមិញ ខ្ញុំទទួលស្គាល់ថាផែនការរៀបចំដែនដី បានគិតគូរពិចារណារាល់កង្វល់របស់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការកសាងផែនការ ដូច្នេះហើយ ភាពសម្បូរបែបនៃសម្បត្តិធម្មជាតិនិងវប្បធម៌មូលដ្ឋានគឺជាចំណុចកណ្តាលនៃផែនការនេះ។ ខ្ញុំសង្ឃឹមថា រដ្ឋបាលខេត្ត

និងរដ្ឋបាលចំណុះខេត្ត នឹងប្រើផែនការរៀបចំដែនដីនេះជាឧបករណ៍នាំផ្លូវសម្រាប់ដំណើរការអភិវឌ្ឍនាពេលអនាគតរបស់ខេត្ត។"

ផែនការរៀបចំដែនដី គឺជាឯកសារយុទ្ធសាស្ត្រគោលនយោបាយសំខាន់មួយ ដែលផ្តល់នូវចក្ខុវិស័យនិងគោលដៅអភិវឌ្ឍរយៈពេលវែងសម្រាប់រយៈពេល ២០ ឆ្នាំខាងមុខ (២០២១-២០៤០) ក៏ដូចជាផ្តល់ទិសដៅជាក់លាក់សម្រាប់ការអភិវឌ្ឍដែនដីខេត្ត ដើម្បីធានាឲ្យបាននូវការអភិវឌ្ឍប្រកបដោយនិរន្តភាពដែលផ្សារភ្ជាប់នឹងការអភិរក្ស។ ផែនការរៀបចំដែនដី ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការកើនឡើងរបស់សហគមន៍មូលដ្ឋាន បញ្ហាប្រឈមនៃការអភិវឌ្ឍ និងការប្រែប្រួលនៃប្រព័ន្ធបរិស្ថាន វប្បធម៌ និងសេដ្ឋកិច្ចសង្គមនៅក្នុងខេត្ត។

ឯកឧត្តម ស្វាយ សំអ៊ាង អភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី និងជាប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្ត មានក្តីសាទរចំពោះការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធ រួមមានអាជ្ញាធរថ្នាក់ខេត្ត ថ្នាក់មូលដ្ឋាន សហគមន៍មូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល ម្ចាស់ជំនួយ អ្នកជំនាញបច្ចេកទេស និងវិស័យឯកជន ដែលសម្រេចបាននូវលទ្ធផលនៃការបង្កើតផែនការរៀបចំដែនដីនេះ។ ឯកឧត្តម បានមានប្រសាសន៍បន្ថែមថា៖ "ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី មានទិសដៅផ្តល់ឥទ្ធិពលលើការសម្រេចចិត្តនិងកសាងភាពជាម្ចាស់រួមគ្នាលើការអភិវឌ្ឍប្រកបដោយគុណភាពរវាងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាព ការអភិវឌ្ឍសេដ្ឋកិច្ច និងការទទួលបាននូវសេវាសាធារណៈប្រកបដោយសមធម៌" ។

លោកស្រី ហាញ ង្វយយេន(Hanh Nguyen) នាយកបេសកកម្មស្តីទី របស់ទីភ្នាក់ងារសហរដ្ឋអាមេរិក សម្រាប់ការអភិវឌ្ឍអន្តរជាតិ (*USAID*) បានមានប្រសាសន៍ថា៖ "ទីភ្នាក់ងារសហរដ្ឋអាមេរិក សម្រាប់ការអភិវឌ្ឍអន្តរជាតិសង្ឃឹមថា ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី នឹងត្រូវបានប្រើជាឧបករណ៍យុទ្ធសាស្ត្រមួយដើម្បីតម្រង់ទិសដៅជាអាទិភាពសម្រាប់ការអភិវឌ្ឍ និងការអភិរក្សខេត្តដ៏ស្រស់ស្អាតមួយនេះ តាមរយៈការដោះស្រាយតម្រូវការបច្ចុប្បន្ន និងការធានាបាននូវការអភិវឌ្ឍប្រទេសកម្ពុជាប្រកបដោយនិរន្តភាពរយៈពេលវែង និងមានការបំភាយឧស្ម័នកម្រិតទាប"។

ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី គឺជាផែនទីបង្ហាញផ្លូវសម្រាប់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាពនិងមានការទទួលខុសត្រូវ និងគុណភាពនៃការបែងចែក ប្រើប្រាស់ដីធ្លី ធនធានធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសនិងសង្គម ដោយផ្អែកលើតម្រូវការជាក់ស្តែងរបស់ខេត្ត និងគោលការណ៍ច្បាប់ ការចូលរួម និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធពីគ្រប់ស្ថានប័ននិងភាគីពាក់ព័ន្ធទាំងអស់។

លោក សេង ទៀក នាយកអង្គការ WWF កម្ពុជា បានមានប្រសាសន៍ថា៖ "នវានុវត្តន៍ចម្បងៗបំផុតនៅក្នុងវិធីសាស្ត្រគ្រប់គ្រងតំបន់ទេសភាព គឺការទទួលស្គាល់នូវតម្រូវការដើម្បីដោះស្រាយអន្តរកម្មដ៏សាំញ៉ាំនៃវិសាលភាពការប្រើប្រាស់ដែនដី រួមទាំងការយល់ដឹងអំពីស្ថាប័ននិងអាកប្បកិរិយារបស់មនុស្សក្នុងនៅទីនោះផងដែរ"។ លោក សេង ទៀក បានមានប្រសាសន៍បន្ថែមទៀតថា៖ "អង្គការ WWF កម្ពុជា ត្រៀមខ្លួនជាស្រេចដើម្បីគាំទ្ររដ្ឋាភិបាលក្នុងការរៀបចំផែនការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តភាពដើម្បីថែរក្សាការពារជីវៈចម្រុះសម្បូរបែបនៅក្នុងខេត្តមណ្ឌលគិរី"។

តំណភ្ជាប់ទៅរូបភាព

**ព័ត៌មានបន្ថែម សូមទាក់ទង៖**

កញ្ញា រ៉ាវី សុភារ័ត្ន
មន្ត្រីកិច្ចការសាធារណៈ អង្គការWWF
លេខទំនាក់ទំនង 017577075
Email: Sophearoth.ravy@wwf.org.kh